**Disability Rights California**

*បណ្តាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា* (California)

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

## តើខ្ញុំ អាចធ្វើដូចម្តេចខ្លះទៅ ក្នុងករណីខ្ញុំមិនយល់ស្របជាមួយនឹងបញ្ហាការកាត់ថវិកានេះ? – ថ្ងៃទី13 ខែសីហា ឆ្នាំ2009

ប្រសិនបើអ្នក មានកង្វល់អំពីការបញ្ហាការកាត់ថវិកាទាំងនេះ អ្នកមានជម្រើសជាច្រើនសម្រាប់រកមេធាវីការពារ។ ជាបឋម និង សំខាន់បំផុតនោះ ប្រសិនបើអ្នកគិតថាការកាត់ទាំងនេះ ត្រូវបានគេអនុវត្តមិនត្រឹមត្រូវនោះ អ្នកអាចដាក់ពាក្យស្នើសុំឲ្យមានសវនាការសើរើមួយបាន។ DRC បានចុះផ្សាយនៅខ្លឹមសារលិខិតមួយចំនួនដែលពន្យល់ប្រាប់អំពីបញ្ហានៃការកាត់ទាំងនេះ។ សូមមេត្តាមើលខ្លឹមសារលិខិតទាំងនោះសម្រាប់ព័ត៌មានអំពីរបៀបរបបដែលអ្នកអាចដាក់ពាក្យស្នើសុំឲ្យមានសវនាការសើរើមួយឡើង។ ប្រសិនបើអ្នក ចង់ឲ្យអត្ថប្រយោជន៍របស់អ្នកបានបន្តក្នុងកម្រិតមួយដែលវាមាននៅមុនការកាត់ថវិកា ខណៈដែលអ្នកកំពុងរង់ចាំអង្គសវនាការសើរើមួយ វាសំខាន់ណាស់សម្រាប់អ្នកត្រូវមើលកម្មវិធីការងារសម្រាប់ទទួលបាន "ជំនួយដែលមិនទាន់បានទូទាត់។" សូមមើលខ្លឹមសារលិខិតនានាស្តីពីបញ្ហាថវិកា និង ប្រភពព័ត៌មានគាំទ្រផ្សេងទៀតរបស់ DRC សម្រាប់ព័ត៌មានបន្ថែមទៀត។

បន្ថែមលើសពីនេះ អ្នកអាចទូរស័ព្ទទាក់ទងសមាជិកសភា ព្រឹទ្ធសភាប្រចាំរដ្ឋ និង អ្នកភិបាលរដ្ឋរបស់អ្នកឲ្យពន្យល់អំពីរបៀបដែលការកាត់ថវិការទាំងនេះមានផលប៉ះពាល់ដល់អ្នក។  សូមមើល http://www.leginfo.ca.gov/yourleg.html ដើម្បីរកមើលអ្នកថាតើអ្នកណាជាសមាជិកសមាជិកាសភា ឬ ព្រឹទ្ធសភាប្រចាំនៅរដ្ឋរបស់អ្នក។  សូមមើល http://gov.ca.gov/interact#contact ដើម្បីរកមើលការិយាល័យតំណាងរបស់អភិបាលរដ្ឋដែលមាននៅតាមមូលដ្ឋាន និង នៅជិតអ្នកបំផុត។  បើទោះជាថវិកានេះ ត្រូវបានបញ្ជូនរួចរាល់ហើយសម្រាប់ឆ្នាំសារពើភ័ណ្ឌ 2009-2010 រដ្ឋបោះឆ្នោតជ្រើសរើសមន្ត្រីអាចនៅតែចង់ស្តាប់លឺនូវអ្វីដែលអ្នកត្រូវនិយាយអំពីផលប៉ះពាល់នៃការកាត់ទាំងនេះទៅលើអ្នក។